CITY OF LONG BEACH

# PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 10 ខែមិថុនា ឆ្នាំ 2021
ទំនាក់ទំនង ៖ ស៊ូហ្សាន ចូន (Susan Jones) អ្នកគ្រប់គ្រងសេវាបណ្ណាល័យចំបង, 562.570.6288, Susan.Jones@lbpl.org

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# បណ្ណាល័យសាធារណៈ ឡុងប៊ិច មានបំណងប្រមូលព័ត៌មាន ជាធាតុចូល ពីសហគមន៍

ឡុងប៊ិច, CA - បណ្ណាល័យសាធារណៈ ឡុងប៊ិច (LBPL) បានដាក់ឱ្យដំណើរការស្ទង់មតិ ដើម្បីកំណត់អោយច្បាស់ អំពីចំណាប់អារម្មណ៍ និងសេចក្តីប្រាថ្នារបស់សហគមន៍ ចំពោះផ្នែកផ្សេងៗ នៃសេវា ។ ឥឡូវនេះ កម្រងសំណួរស្ទង់មតិ អាចរកបាន នៅលើអ៊ីនធឺណែត រហូតដល់ថ្ងៃទី 28 ខែសីហា ហើយមានផ្តល់ជូន ជាភាសា អង់គ្លេស, អេស្ប៉ាញ, ខ្មែរ និង តាហ្គាឡុក ។ ឯកសារកម្រងសំណួរ ក៏មានផ្តល់ជូន ជាពហុភាសាផងដែរ ហើយអាចរកបាន នៅគ្រប់ទីតាំងបណ្ណាល័យទាំងអស់ ដែលផ្តល់សេវា មកយក & ចេញទៅ (Grab & Go) និង LBPL To-Go ។

ចៅហ្វាយក្រុង រ៉ូប៊ើត ហ្គាសៀ (Mayor Robert Garcia) «បណ្ណាល័យ គឺជា ធនធានយ៉ាងសំខាន់ ចំពោះភូមិស្ថានរបស់យើង ហើយធាតុចូល ពីសហគមន៍របស់យើង មានសារៈសំខាន់ណាស់ ចំពោះការធ្វើផែនការប្រតិបត្តិការ របស់យើងខ្ញុំ ។» «ខ្ញុំលើកទឹកចិត្តប្រជាពលរដ្ឋ ឱ្យចូលរួមបំពេញ កម្រងសំណួរស្ទង់មតិ របស់បណ្ណាល័យយើង ។ មតិត្រឡប់ពីលោកអ្នក មានសារៈសំខាន់ណាស់ សម្រាប់យើងខ្ញុំ ហើយជួយយើងខ្ញុំឱ្យអាចសម្រេចបាន គោលដៅរបស់យើងខ្ញុំ ក្នុងការធានាឱ្យសេវាបណ្ណាល័យ អាចបំពេញបានតាមសេចក្តីត្រូវការ របស់ប្រជាពលរដ្ឋឡុងប៊ិចទាំងអស់គ្នា ។»

កម្រងសំណួរស្ទង់មតិ LBPL ព្យាយាមទាញយក ព័ត៌មានត្រឡប់ ពីសហគមន៍ ក្នុងផ្នែកដូចជា ម៉ោងដំណើរការបណ្ណាល័យ ព័ត៌មានអំពីបណ្ណាល័យ និងបច្ចេកវិទ្យា បែបសម្របលក្ខណៈ និងបែបជំនួយ ។ គោលដៅនៃការស្ទង់មតិនេះ គឺដើម្បីកំណត់រកសេវាណា ដែលមានសារៈសំខាន់បំផុត ចំពោះភ្ញៀវបណ្ណាល័យ និងផ្តល់ឱកាសឱ្យពួកគេ អាចផ្តល់ មតិយោបល់បាន ។

កម្រង់សំណួរជាឯកសារក្រដាស អាចរកបាននៅទីតាំង LBPL To-Go ដូចខាងក្រោមនេះ នៅថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍ ចាប់ពីពេលថ្ងៃត្រង់ ដល់ម៉ោង 7 យប់; នៅថ្ងៃពុធ ចាប់ពីពេលថ្ងៃត្រង់ ដល់ម៉ោង 6 ល្ងាច និងនៅថ្ងៃសុក្រ និងថ្ងៃសៅរ៍ ចាប់ពីម៉ោង 10 ព្រឹក ដល់ម៉ោង 5 ល្ងាច ៖

- បណ្ណាល័យ ចំបង ប៊ីលលី ជែន ឃីង (Billie Jean King Main Library), 562.570.7500
- ប៊េសរ៍ (Bay Shore), 562.570.1039
- អ៊ែល ដូរ៉ាដូ (El Dorado), 562.570.3136
- ប្រ៊េត ហាត (Bret Harte), 562.570.1044
- ឡូសអាល់តូស (Los Altos), 562.570.1045
- ម៉ាកត្វេន (Mark Twain), 562.570.1046
- មីសែល អូបាម៉ា (Michelle Obama), 562.570.1047

CITY OF LONG BEACH

# PRESS RELEASE

ហ្គ្លែនដា វីលលាម (Glenda Williams) នាយកបណ្ណាល័យសាធារណៈ ឡុងប៊ិច បានគូសបញ្ជាក់ថា «បណ្ណាល័យសាធារណៈ ឡុងប៊ិច ត្រូវបានបង្កើតឡើង អស់រយៈពេល 125ឆ្នាំ មកហើយ និងមានប្រវត្តិ ដ៏យូរលង់មកហើយ ក្នុងការសម្របខ្លួន ដើម្បីឱ្យអាចបំពេញបាន តាមសេចក្តីត្រូវការ របស់សហគមន៍ ។» «យើងខ្ញុំចង់ដឹងពីមតិយោបល់ របស់អ្នកប្រើប្រាស់បណ្ណាល័យទាំងអស់ សូម្បីតែអ្នកដែលមិនប្រើប្រាស់បណ្ណាល័យរបស់យើង នាពេលបច្ចុប្បន្ននេះក្តី ដើម្បីជួយយើងខ្ញុំ ក្នុងការធ្វើផែនការ សម្រាប់ពេលអនាគត ដើម្បីធានាថា អ្នកគ្រប់គ្នាទទួលបានកិច្ចស្វាគមន៍ និងចំណាយពេល ចូលបណ្ណាល័យតាមភូមិស្ថានរបស់ពួកគេ ។»

កម្រងសម្បត្តិ បច្ចុប្បន្ន របស់ LBPL រួមមាន វត្ថុ និងឯកសារបោះពុម្ព លក្ខណៈផ្តោតពិសេស, កំណត់ត្រា, DVDs, សៀវភៅអេឡិចត្រូនិក, សៀវភៅសម្លេង ដែលអាចទាញយកបាន, វីដេអូ និងតន្ត្រី ព្រមទាំង ក្រូមប៊ុក (Chromebooks) និងដុំអ៊ីនធឺណែតឥតខ្សែ (wireless hotspots) ក្នុងចំនួន ជាង 800,000 ដែលអាចឱ្យអ្នកប្រើប្រាស់ខ្ចីចេញបាន ។ បណ្ណាល័យឌីជីថល រួមមាន ធនធាន សម្រាប់ការរៀនភាសា, ធ្វើកិច្ចការគ្រូដាក់ឱ្យធ្វើនៅផ្ទះ និងជំនួយ ផ្នែកការងារ, ថ្នាក់បង្រៀនវិជ្ជាជីវៈ និងបច្ចេកទេស, សកម្មភាពធ្វើពេលទំនេរ, កម្រងសិក្សា អំពីសាច់សារលោហិតគ្រួសារ និងព័ត៌មាន ។

គំនិតដាក់ឱ្យធ្វើការស្ទង់មតិសហគមន៍នេះ ដើមឡើយ កើតចេញពីសំណើ នៅកិច្ចប្រជុំក្រុមប្រឹក្សាក្រុងឡុងប៊ិច ដើម្បីសិក្សា អំពីម៉ោងដំណើរការបណ្ណាល័យ ។

សម្រាប់ព័ត៌មាន បន្ថែមទៀត អំពីការស្ទង់មតិនេះ ឬសេវាបណ្ណាល័យ សូមចូលទៅ www.lbpl.org/ ឬទូរសព្ទទៅលេខ 562.570.7500 ។ “ចុចចូលចិត្ត (Like)” ទំព័រ Long Beach Public Library នៅលើ Facebook, ហើយ តាមទំព័រឈ្មោះនេះ នៅលើ Twitter និង Instagram។

# # #